**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តមណ្ឌលគិរី**

សំណុំរឿងព្រហ្មទណ្ឌលេខ៖២០០

ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

សាលក្រមព្រហ្មទណ្ឌលេខ៖៣៣"ខ"

ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តមណ្ឌលគិរី

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

និងប្រកាសសាលក្រម នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

ដែលមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

### សមាសភាពចៅក្រមជំនុំជម្រះ

លោក [redacted] អនុប្រធានសាលាដំបូង ជាចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តមណ្ឌលគិរី

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តមណ្ឌលគិរី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖២០០ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ៖

១.ឈ្មោះ [redacted] ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិព្នង សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតនៅភូមិពូលូង ឃុំរមនា ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី មានទីលំនៅបច្ចុប្បន្ននៅភូមិពូលូង សង្កាត់សែនមនោរម្យ ខេត្តមណ្ឌលគិរី ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៣នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖ គ្មាន ជាទីតិជន។ (ដីកាសម្រេចដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ៖ ១២/២២ "គ" ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២)

២.ឈ្មោះ [redacted] ហៅ ពុកកែវ ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិព្នង សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិខ្ទង់ ឃុំស្រែខ្ទុម ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី មានទីលំនៅបច្ចុប្បន្ននៅភូមិពូលូង សង្កាត់សែនមនោរម្យ ខេត្តមណ្ឌលគិរី ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៤នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖ គ្មាន ជាទីតិជន។ (ដីកាសម្រេចដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ៖ ១៣/២២ "គ" ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២)

៣.ឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិព្នង សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតនៅភូមិពូលូង សង្កាត់សែនមនោរម្យ ខេត្តមណ្ឌលគិរី ទីលំនៅបច្ចុប្បន្ននៅភូមិពូលូង សង្កាត់សែនមនោរម្យ ខេត្តមណ្ឌលគិរី ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០២នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖ គ្មាន ជាទីតិជន។ (ដីកាសម្រេចដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ៖ ១៤/២២ "គ" ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២)

៩.ឈ្មោះ [redacted] ភេទស្រី អាយុ ៥៥ឆ្នាំ ជនជាតិព្នង សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតនៅភូមិពូលុង សង្កាត់សែនមនោរម្យ ខេត្តមណ្ឌលគិរី មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិពូលុង សង្កាត់សែនមនោរម្យ ខេត្តមណ្ឌលគិរី និងកូនឈ្មោះ [redacted] វី(ស្លាប់) ម្តាយឈ្មោះ [redacted] ប៉ុ(រស់) ប្តីឈ្មោះ [redacted] មានកូនចំនួន០៧នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុខ៖គ្មាន ជាតិតជន។ (ដីកាសម្រេចដាក់ឃុំខ្លួនក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ៖ ០១/២២ "ត" ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២២)

ជាប់ចោទពីបទ៖ ញុះញង់ឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅភូមិពូលុង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-បានឃើញ ដីកាដំណោះស្រាយលេខ៖ ១៦០២/២២(ង) ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២។

-បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ៖ ៥៨ ដពស/២៣ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣។

-ឈ្មោះ [redacted] ភេទប្រុស អាយុ៦០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិពូលុង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ជាដើមបណ្តឹងរដ្ឋប្បវេណី។

## <u>អង្គហេតុ និងដំណើររឿងមានដូចតទៅ</u>

កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ [redacted] ព្រមទាំងប្រជាពលរដ្ឋនៅភូមិពូលុង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី បាននាំគ្នាលក់ដីមួយកន្លែងស្ថិតនៅភូមិពូលុង សង្កាត់រមនា ទៅឱ្យឈ្មោះ [redacted] ភេទប្រុស អាយុ ៥០ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ៤៩ឆ្នាំ និងបានចែកប្រាក់គ្នាបានចំនួន ៨០០.០០០រៀល លុះដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ស្រាប់តែឈ្មោះ [redacted] និងឈ្មោះ [redacted] បានឱ្យឈ្មោះ [redacted] និងបក្សពួក ទៅកាប់ឆ្ការព្រៃនៅលើដីនោះ ក៏ស្រាប់តែឈ្មោះ [redacted] ហៅ [redacted] ឈ្មោះ [redacted] ហៅ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] បានទៅញុះញង់ប្រជាពលរដ្ឋរស់នៅក្នុងភូមិឱ្យចាប់ម៉ាស៊ីនរបស់បក្សពួកឈ្មោះ [redacted]។

## <u>ការពោលសារភាព៖</u>

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនសូមបដិសេធពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ទាំងស្រុង ពីព្រោះខ្លួន ពុំបានទៅញុះញង់ប្រជាពលរដ្ឋនៅក្នុងភូមិពូលុង និងទៅគំរាមកំហែងសម្លាប់ លោក [redacted] នោះទេ។ កាលពីថ្ងៃខែឆ្នាំមិនចាំ ក្មួយប្រុស របស់ខ្លួនឈ្មោះ [redacted] បានមកប្រាប់ខ្លួនថា "ពួកអ្នកមិនទៅបើកប្រាក់ពីគេទេ គេទៅបើកអស់មួយភូមិហើយ នៅផ្ទះលោក [redacted]" ខ្លួនបានឮដូច្នោះ ក៏បានទៅផ្ទះឈ្មោះ [redacted] មានមុខរបរ ជាមេឃុំសង្កាត់រមនា ពេលទៅដល់ឃើញមាន

ប្រពន្ធឈ្មោះរបស់ឈ្មោះ [redacted] និងបុរសម្នាក់ទៀតពុំស្គាល់ឈ្មោះ។ ពេលទៅដល់ភ្ជាម ប្រពន្ធរបស់ឈ្មោះ [redacted] បានមើលក្នុងក្រដាសឃើញមានឈ្មោះរបស់ខ្លួន ក៏បានហុចលុយចំនួន ៨០០.០០០រៀល ហើយឱ្យខ្លួនចុះហត្ថលេខា រួចខ្លួនក៏ត្រឡប់មកផ្ទះវិញ ដោយពុំសួរនាំអ្វីពីប្រពន្ធឈ្មោះ [redacted] នោះទេ។ លុះរំលងបាន៣ថ្ងៃក្រោយ ឈ្មោះ [redacted] មកប្រាប់ថា លុយដែលខ្លួនទៅបើកនោះ ជាលុយលក់ភ្នំវាំងក្បាលអូរច្បារ ទើបខ្លួន និងប្រជាពលរដ្ឋនាំគ្នាទៅសួរនាំពីលោកមេភូមិឈ្មោះ [redacted] ប៉ុន្តែគាត់ប្រាប់ថា គាត់មិនដឹងទេ។ ប្រហែលជាកន្លះខែក្រោយ ខ្លួនឃើញគេកាប់គោក្របីសែនព្រេន ពីលើចំណុចភ្នំវាំងក្បាលអូរច្បារ ទើបប្រជាពលរដ្ឋ (មិនចាំចំនួន) នាំគ្នាទៅហាមឃាត់គេមិនឱ្យសែនព្រេន ព្រោះពួកខ្ញុំមិនសុខចិត្តឱ្យគេយកលក់ភ្នំនោះទេ ព្រោះពួកគេឈូសឆាយ និងផ្តួលរំលំដើមឈើធំៗ ធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹកក្បាលអូរច្បារ។ ទើបអ្នកទិញគាត់កំណត់ដោយការទាញម៉ែត្រវាស់ខណ្ឌចែកគ្នា ដោយកំណត់ពីចំណុចដាក់ស្រាពាងសែនព្រេន ប្រវែង ១០០ម៉ែត្រ ទៅទិសខាងត្បូង ប្រគល់ឱ្យអ្នកភូមិ ចំណែកអ្នកទិញ គឺគិតចាំពីចំណុចហួស ១០០ម៉ែត្រ របស់អ្នកភូមិ ទៅជាកម្មសិទ្ធិរបស់គាត់។ រំលងបាន០១ខែ ខ្លួនឃើញមានគេយកគ្រឿងចក្រមកឈូសឆាយនៅភ្នំវាំង ប្រជាពលរដ្ឋទាំងក្មេងទាំងចាស់ ក៏បានចុះទៅសួរនាំ និងហាមឃាត់ ទើបម្ចាស់គ្រឿងចក្រ យកគ្រឿងចក្រត្រឡប់ទៅវិញ។ ក្រោយមកទៀតខ្លួន និងប្រជាពលរដ្ឋបានលឺសម្លេងម៉ាស៊ីនអាឈើនៅចំណុចភ្នំវាំងក្បាលអូរច្បារ ទើបពួកយើងនាំគ្នាទៅមើលដោយមានប្រជាពលរដ្ឋចំនួនប្រហែល ២០នាក់(មានស្រី មានប្រុស) បាននាំគ្នាទៅហាមឃាត់កម្មករចំនួន ០២នាក់ ដែលកំពុងកាន់ម៉ាស៊ីនអាឈើ ហើយប្រជាពលរដ្ឋទាំងស្រី ទាំងប្រុស បានស្រែកឱ្យទៅចាប់យកម៉ាស៊ីនអាឈើនោះ ទើបខ្លួនចូលទៅចាប់យកម៉ាស៊ីន បន្តិចក្រោយមក ខ្លួនឃើញលោក [redacted] មកជួបនិយាយជាមួយខ្លួនថា មេចបានមកយកម៉ាស៊ីនរបស់គាត់ ហើយខ្លួននិយាយថា ម៉េចបានមកកាប់ព្រៃនៅកន្លែងដំណាម (កន្លែងជំនឿរបស់អរក្សអ្នកតា ម្សិលម្ងៃមកកាប់ម្តងហើយនឹងកាំបិត ម្តេចថ្ងៃនេះយករណាមកកាត់វិញអញ្ចឹង រួចខ្លួនក៏យកម៉ាស៊ីននោះទៅទុកនៅផ្ទះរបស់ឈ្មោះ [redacted] តែម្តង។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនសូមបដិសេធពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២០ ចោលទាំងស្រុង ពីព្រោះខ្លួន ពុំបានទៅញុះញង់ប្រជាពលរដ្ឋនៅក្នុងភូមិពួលល្វង និងទៅគំរាមកំហែងសម្លាប់ លោក [redacted] នោះទេ។ ខ្លួនពុំបានទទួលលុយចំនួន ៨០០.០០០រៀល ពីប្រពន្ធឈ្មោះ [redacted] ឬពីឈ្មោះ [redacted] ផ្ទាល់នោះទេ ប្រពន្ធរបស់ខ្លួនជាអ្នកទទួលនៅឯផ្ទះរបស់បងឈ្មោះ [redacted]។ រំលងបានបីថ្ងៃ ប្រជាពលរដ្ឋនាំគ្នាទៅសួរនាំមេភូមិ ហើយលោកមេភូមិថាមិនដឹងជាំលុយអ្វីដែរ។ រឿងហេតុទាក់ទង និងការលក់ភ្នំវាំង ក៏ខ្លួនដឹងក្រោយគេ ខ្លួនដឹងនៅពេលឃើញគេកាប់ក្របីសែនព្រេន ពីលើចំណុចភ្នំវាំងក្បាលអូរច្បារ ទើប្រជាពលរដ្ឋ(មិនចាំចំនួន) នាំគ្នាទៅហាមឃាត់គេមិនឱ្យសែនព្រេន ព្រោះពួកខ្ញុំមិនសុខចិត្តឱ្យគេយកលក់ភ្នំនោះទេ ព្រោះពួកគេឈូសឆាយ និងផ្តួលរំលំដើមឈើធំៗ ធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹកក្បាលអូរច្បារ។ រំលងបាន០១ខែ ខ្លួនឃើញមានគេយកគ្រឿងចក្រមកឈូសឆាយនៅភ្នំវាំង ប្រជាពលរដ្ឋក៏បានចុះទៅសួរនាំ និងហាមឃាត់ ឱ្យបញ្ឈប់សកម្មភាពឈូសឆាយដី និងផ្តួលរំលំដើមឈើធំៗប៉ះពាល់ដល់កន្លែងសែនព្រេន និងផ្នូរខ្មោចដូនតា ហើយម្ចាស់គ្រឿងចក្រ ក៏បានយកគ្រឿងចក្រត្រឡប់ទៅវិញ។ ក្រោយមកទៀតខ្លួន និងប្រជាពលរដ្ឋបានលឺសម្លេង

ម៉ាស៊ីនអារឈើនៅចំណុចភ្នំវ៉ាំងក្បាលអូរច្បារ ទើបពួកយើងនាំគ្នាទៅមើលដោយមានប្រជាពលរដ្ឋចំនួនប្រហែល ១០នាក់ បាននាំគ្នាទៅហាមឃាត់កម្មករចំនួន២នាក់ ដែលកំពុងកាន់ម៉ាស៊ីនអារឈើ បន្តិតក្រោយមក លោក [redacted] មកជួបនិយាយជាមួយខ្លួន ហើយឈ្មោះ [redacted] ក៏ចូលមកយកម៉ាស៊ីនអាឈើទៅទុកនៅផ្ទះរបស់ខ្លួន ហើយខ្លួនក៏ពុំបាននិយាយអ្វី ឬប្រើប្រាស់ពាក្យសំដីអ្វី គម្រាមកំហែងដល់ឈ្មោះ [redacted] នោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនសូមបដិសេធពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ ចោលទាំងស្រុង ពីព្រោះខ្លួនពុំបានទៅញុះញង់ប្រជាពលរដ្ឋនៅក្នុងភូមិពូល្វង និងទៅគម្រាមកំហែងសម្លាប់ លោក [redacted] នោះទេ។ ខ្លួនពុំបានទទួលលុយចំនួន ៨០០.០០០រៀល ពីប្រពន្ធឈ្មោះ [redacted] នោះទេ។ ចំណែករឿងហេតុទាក់ទង និងការលក់ភ្នំវ៉ាដាង ក៏ខ្លួនដឹងក្រោយគេ ខ្លួនដឹងនៅពេលឃើញគេកាប់ក្របីសែនព្រៃន ពីលើចំណុចភ្នំវ៉ដាងក្បាលអូរច្បារ ទើបប្រជាពលរដ្ឋ(មិនចាំចំនួន) នាំគ្នាទៅហាមឃាត់គេមិនឱ្យសែនព្រៃន ព្រោះពួកខ្ញុំមិនសុខឱ្យគេយកលក់ភ្នំនោះទេ ព្រោះពួកគេឈូសឆាយ និងផ្តួលរំលំដើមឈើធំៗ ធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹកក្បាលអូរច្បារ។ ទើបអ្នកលក់កំណត់ដោយការទាញម៉ែត្រវាស់ខណ្ឌចែកគ្នា ដោយកំណត់ពីចំណុចដាក់ស្រាពាងប្រហែល ១០០ម៉ែត្រ ទៅទិសខាងត្បូង ប្រគល់ឱ្យអ្នកភូមិ ចំណែកអ្នកលក់ គឺគិតចាប់ពីចំណុច ហួស ១០០ម៉ែត្រ របស់អ្នកភូមិ ទៅជាកម្មសិទ្ធិរបស់គាត់។ រំលងបាន០១ខែ ខ្លួនឃើញមានគេយកគ្រឿងចក្រមកឈូសឆាយនៅភ្នំវ៉ាដាង ប្រជាពលរដ្ឋក៏បានចុះទៅសួរនាំ និងហាមឃាត់ ចំណែកម្ចាស់គ្រឿងចក្រ មកឈូសឆាយនៅភ្នំវ៉ាដាង ប្រជាពលរដ្ឋក៏បានចុះទៅសួរនាំ និងហាមឃាត់ ដោយម្ចាស់គ្រឿងចក្រថា គេជួលខ្ញុំឱ្យមកឈូសឆាយពីលើភ្នំរហូតដល់ផ្លូវជាតិ ហើយប្រជាពលរដ្ឋក៏បានហាមឃាត់ ចំណែកម្ចាស់គ្រឿងចក្រ ក៏បានយកគ្រឿងចក្រត្រឡប់ទៅវិញ។ ក្រោយមកទៀតខ្លួន និងប្រជាពលរដ្ឋបានលឺសម្លេងម៉ាស៊ីនអាឈើនៅចំណុចភ្នំវ៉ាដាក្បាលអូរច្បារ ទើបពួកយើងនាំគ្នាទៅមើល មានប្រជាពលរដ្ឋចំនួនប្រហែល ១០នាក់ បាននាំគ្នាទៅហាមឃាត់កម្មករចំនួន ០២នាក់ ដែលកំពុងកាន់ម៉ាស៊ីនអាឈើ បន្តិតក្រោយមក ខ្លួនក៏ឃើញលោក [redacted] មកជួបនិយាយជាមួយឈ្មោះ [redacted] ហើយឈ្មោះ [redacted] ក៏បានឱ្យឈ្មោះ [redacted] យកម៉ាស៊ីនអាឈើយកទៅទុកនៅផ្ទះរបស់គាត់ ហើយខ្លួនក៏ត្រឡប់មកផ្ទះវិញជាមួយឈ្មោះ [redacted] ផងដែរ។ ខ្លួនសូមបញ្ជាក់ថា៖ ពុំបានញុះញង់ឱ្យប្រជាពលរដ្ឋក្នុងភូមិដោយមកហាមឃាត់កម្មករ ដែលកំពុងកាត់ព្រៃនោះទេ គឺប្រជាពលរដ្ឋស្ម័គ្រចិត្តដោយខ្លួនដោយសាររកន្លែងកាប់ព្រៃនោះជាកន្លែងដំណម និងជាប្រភពទឹកប្រើប្រាស់របស់ជាពលរដ្ឋទូទាំងភូមិពូល្វង។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនសូមបដិសេធពាក្យបណ្តឹងឈ្មោះ [redacted] ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ ចោលទាំងស្រុង ពីព្រោះខ្លួនពុំបានទៅញុះញង់ ឬដើរហៅប្រជាពលរដ្ឋនៅក្នុងភូមិពូល្វងឱ្យទៅរារាំង ឬបញ្ឈប់សកម្មភាពរបស់កូនចៅលោក [redacted] នោះទេ។ ខ្លួនពិតជាបានទៅទទួលប្រាក់ពីប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ចំនួន ៨០០.០០០រៀល នៅឯផ្ទះរបស់ឈ្មោះ [redacted] និងបានឱ្យខ្លួនផ្តិតមេដៃលើក្រដាស (ក្រដាស់សៀវភៅក្មេងរៀន) ហើយកូនខ្លួនក៏បានសួរថាជាលុយអ្វី ទើបប្រពន្ធឈ្មោះ [redacted] ឆ្លើយថាលុយចឹងៗគេមិនប្រាប់នោះទេ បើខ្លួនដឹងថាលុយលក់ភ្នំវ៉ាដាង នាងខ្ញុំពុំព្រមយកនោះទេ។ ក្រោយពេលដឹងថាជាលុយលក់ភ្នំ ហើយ ខ្លួនក៏បានយកលុយទាំងនោះទៅសងឈ្មោះ [redacted] ភេទស្រី ជនជាតិខ្មែរ ដោយយកលុយទៅសងនៅ

ផ្ទះរបស់ឈ្មោះ [redacted] ដោយឈ្មោះ [redacted] ធានាអះអាងថាយកលុយទៅសងឈ្មោះ [redacted] និងជួយដោះស្រាយយកដីភ្នំមកវិញឱ្យបាន ប៉ុន្តែក្រោយពេលទទួលបានលុយហើយឈ្មោះនេះរត់បាត់។ រំលងបាន៤ថ្ងៃក្រោយពីទទួលលុយហើយ ខ្លួនក៏ឃើញគេកាប់ក្របីសែនព្រៃន ពីលើចំណុចភ្នំរ៉ាដាងក្បាលអូរឡោរ ទើបប្រជាពលរដ្ឋ(មិនចាំចំនួន)នាំគ្នាទៅហាមឃាត់គេមិនឱ្យសែនព្រៃន ព្រោះពួកខ្ញុំមិនសុខចិត្តឱ្យគេយកលក់ភ្នំនោះទេ ព្រោះពួកគេឈូសឆាយ និងផ្តួលរំលំដើមឈើធំៗ ធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹកក្បាលអូរឡោរ។ ទើបអ្នកលក់កំណត់ដោយការទាញម៉ែត្រវាស់ខណ្ឌចែកគ្នា ដោយអ្នកលក់យកផ្នែកខាងលើភ្នំ ចំណែកអ្នកភូមិយកផ្នែកខាងក្រោយរហូតដល់ផ្លូវជាតិ។ ក្រោយមកទៀតខ្លួន និងប្រជាពលរដ្ឋបានលឺសម្លេងម៉ាស៊ីនអាឈើនៅចំណុចភ្នំរ៉ាដាងក្បាលអូរឡោរទើបពួកយើងនាំគ្នាទៅមើលដោយមានប្រជាពលរដ្ឋចំនួន ប្រហែល ១០នាក់ ពួកខ្លួនក៏បានចាប់យកម៉ាស៊ីនអាឈើ ពីកូនចៅលោក[redacted]ហើយកូនចៅគាត់បានខលទូរស័ព្ទហៅលោក[redacted] មកជួបពួកខ្លួន ពេលលោក[redacted] មកដល់សួរពួកខ្លួនថា មេចបានមកចាប់ម៉ាស៊ីនអាឈើខ្ញុំបែបនេះ ក្រែងព្រមព្រៀងគ្នាលក់ដីភ្នំ និងយកលុយចាយអស់ហើយតើ? ខ្លួនបានឆ្លើយថា ពួកខ្ញុំបានឯកភាពលក់នៅថ្ងៃកាប់ក្របីសែនព្រៃនលើកមុន ប៉ុន្តែមិនបានលក់ភ្នំរ៉ាដាងក្បាលអូរឡោរទាំងមូលនោះទេ មេចបានមកឈូសឆាយដល់ផ្លូវជាតិព្រោះកន្លែងសែនព្រៃន កន្លែងអារក្សអ្នកតាជាជំនឿរបស់ដូនតាពួកខ្ញុំ ដូច្នេះពួកខ្ញុំពុំព្រមមកឈូសឆាយបន្តទៀតនោះទេ។ ទើបឈ្មោះ [redacted] ចាប់យកម៉ាស៊ីនអាឈើមកទុកនៅឈ្មោះ [redacted] តែម្តង។ ខ្លួនសូមបញ្ជាក់ថា ពុំបានញុះញង់ឱ្យប្រជាពលរដ្ឋក្នុងភូមិដោយមកហាមឃាត់កម្មករ ដែលកំពុងកាត់ព្រៃនោះទេ គឺប្រជាពលរដ្ឋស្មគ្រចិត្តដោយខ្លួន ដោយសារកន្លែងកាត់ព្រៃនោះជាកន្លែងដំណាម និងជាប្រភពទឹកប្រើប្រាស់របស់ជាពលរដ្ឋទូទាំងភូមិពូលូង។

-ដើមបណ្តឹងឈ្មោះ [redacted] បានឆ្លើយថា៖ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ខ្លួន និងប្រជាពលរដ្ឋនៅក្នុងភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី បានព្រមព្រៀងគ្នាលក់ដីមួយកន្លែងស្ថិតនៅភូមិពូលូង ឱ្យទៅឈ្មោះ [redacted] និងឈ្មោះ [redacted] រស់នៅរាជធានីភ្នំពេញ។ ក្រោយពេលទិញលក់រួចហើយខ្លួនក៏បានប្រគល់ប្រាក់ចំនួន ៨០០.០០០រៀល ក្នុងមួយគ្រួសារ ទៅឱ្យប្រជាពលរដ្ឋនៅក្នុងភូមិពូលូង ទាំងមូល ចំណែកឈ្មោះ [redacted] និងឈ្មោះ [redacted] ក៏បានទទួលប្រាក់ចំនួន ៨០០.០០០រៀល ពីខ្លួនផងដែរ។ នៅពេលនោះខ្លួនក៏បានធ្វើលិខិតទទួលប្រាក់ត្រឹមត្រូវដែរ។ លុះដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ នៅពេលដែលឈ្មោះ [redacted] និងឈ្មោះ [redacted] ឱ្យកូនចៅទៅកាប់ស្ការព្រៃនៅលើដីនោះ ស្រាប់តែឈ្មោះ [redacted] , ឈ្មោះ [redacted] និងឈ្មោះ [redacted] បានញុះញង់ប្រជាពលរដ្ឋនៅក្នុងភូមិឱ្យទៅចាប់ម៉ាស៊ីនកាត់ឈើរបស់អ្នកទាំងពីរខាងលើ និងហាមមិនឱ្យកូនចៅរបស់ឈ្មោះ [redacted] និងឈ្មោះ [redacted] មិនឱ្យកាប់ស្ការ និងបានទាមទារយកដីនោះមកវិញ ព្រមទាំងគំរាមកំហែងសម្លាប់ខ្លួនថែមទៀតផង។ ក្នុងរឿងក្តីនេះរវាងក្រុមខ្លួនដែលជាដើមបណ្តឹងដូចមានឈ្មោះខាងលើ ក្នុងសំណុំរឿងនេះ បានប្តឹងគ្នាទៅវិញទៅមកជាមួយនឹងក្រុមជនជាប់ចោទខាងក្រុមជនជាប់ចោទក៏ប្តឹងពីខាងក្រុមខ្លួនក្នុងរឿងតែមួយនេះ។ ពេលនេះខ្លួនយល់ឃើញថា ការប្តឹងគ្នារបៀបនេះខាតពេលវេលា ហត់នឿយអត់ប្រយោជន៍ ខ្លួនសូមបញ្ចប់រឿងក្តីនេះតែប៉ុននេះចុះ។

-ចម្លើយឈ្មោះ [redacted] ជាមេភូមិពូលួង និងជាសាក្សី បានឆ្លើយថា៖ ខ្លួនចូលកាន់តំណែងតាំងពីឆ្នាំ ២០១៧ រហូតដល់បច្ចុប្បន្ន ដោយគ្រប់គ្រងចំនួន ២៦២គ្រួសារ ចំណែកទំហំផ្ទៃដីភូមិ ខ្លួនពុំចាំនោះទេ។ ចំពោះអង្គហេតុខាងលើខ្លួនពុំបានចាំច្បាស់នោះទេ គ្រាន់តែដឹងថា អ្នកដែលញុះញង់ គឺជាប្រជាពលរដ្ឋមកពីភូមិផ្សេង និងក្នុងភូមិពូលួង(ពុំចាំឈ្មោះនោះទេ) ហើយនៅថ្ងៃដែលប្រជាពលរដ្ឋនាំគ្នាទៅចាប់យកម៉ាស៊ីនរបស់ឈ្មោះ [redacted] និងបក្សពួក ខ្លួនពុំដឹងថាមានប្រជាពលរដ្ឋចំនួនប៉ុន្មាននាក់ចូលរួមនោះទេ ព្រោះខ្លួនពុំបានចូលរួម។ លុះក្រោយមកទើបមានពាក្យបណ្ដឹងពីឈ្មោះ [redacted] ទៅវិញ ដោយពួកគាត់ទាំងអស់ពុំមែនជាអ្នកញុះញង់ ឬជាអ្នកគំរាមកំហែងរកសម្លាប់អ្នកណាសោះ។ ខ្លួនសូមជម្រាបថាក្នុងរឿងនេះ ខ្លួនក៏បានទទួលប្រាក់ចំនួន ៨០០.០០០រៀល ពីឈ្មោះ [redacted] និងឈ្មោះ [redacted] ជាប្រាក់ដែលលក់ភ្នំរ៉ាងទំហំ ៣.៧ហិកតា ចុះពីផ្លូវជាតិប្រវែង ៧០ម៉ែត្រ។ នៅក្នុងរឿងលក់ភ្នំនេះមានមនុស្ស ០៩ នាក់ ជាអ្នកឈរឈ្មោះតំណាងអោយប្រជាពលរដ្ឋក្នុងភូមិពូលួង ដោយមានទី១.ឈ្មោះ [redacted] ទី២.ឈ្មោះ [redacted] ទី៤.ឈ្មោះ [redacted] ទី៥.ឈ្មោះ [redacted] ទី៦.ឈ្មោះ [redacted] ទី៧.ឈ្មោះ [redacted] ទី៨.ឈ្មោះ [redacted] និងទី៩.ឈ្មោះ [redacted] ហើយក៏មានឈ្មោះ [redacted] ឈរឈ្មោះជាអ្នកស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីដែលមានលេខ៖ ០៨៦/១៩ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ដោយមានការចុះហត្ថលេខាដោយខ្លួន លោកចៅសង្កាត់ និងលោកអភិបាលក្រុងផងដែរ។ មុនពេលខ្លួនចុះហត្ថលេខាលើពាក្យស្នើសុំកាប់ដីធ្លី ខ្លួនពុំបានចុះទៅពិនិត្យទីតាំងដីដោយផ្ទាល់ទេ គឺមានអ្នកតំណាងដោយអ្នកទិញ និងអ្នកតំណាងឲ្យអ្នកលក់ ព្រមទាំងអ្នកចុចGPF។ ក្រោយពីទិញលក់រួចហើយ ក៏មានការកាប់ក្របីសែនព្រៃន នៅទីតាំងដីខាងលើ ប៉ុន្តែខ្លួនពុំបានចូលរួមនោះទេ រវល់ជូនប្រពន្ធទៅពេទ្យ។ បច្ចុប្បន្នដីនៅទីតាំងខាងលើស្ថិតនៅក្នុងសមត្ថកិច្ចគណៈកម្មការថ្នាក់ខេត្តកំពុងដោះស្រាយ។

-សាក្សីឈ្មោះ [redacted] ភេទប្រុស អាយុ៤៣ឆ្នាំ, ឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ និងសាក្សីឈ្មោះ [redacted] ភេទស្រី អាយុ៦៦ឆ្នាំ ដែលមានទីលំនៅបច្ចុប្បន្ន នៅភូមិពូលួង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ ពួកខ្លួន និងប្រជាពលរដ្ឋមួយចំនួនទៀតបាននាំគ្នាទៅមើលពួកគេមកឈូសឆាយកាប់គាស់រុករានភ្នំដែលជាទីកន្លែងសក្ការៈពីដូនតា គឺពួកខ្លួនមិនព្រមលក់ភ្នំនេះទៅឲ្យគេទេ ទុកជាទីសក្ការៈ។ ពួកខ្លួនដែលនាំគ្នាទៅនេះ គឺគ្មាននរណាបបួល ឬញុះញង់នោះទេ គឺទៅដោយចិត្តឯងតែម្ដង។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ សូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងសូមឲ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការប្ដឹងសុំ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធឲ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការយល់ឃើញថា

-បុព្វបទដើម នៃអង្គហេតុក្នុងរឿងក្ដីនេះ កើតចេញពីជនមួយក្រុមនាំគ្នាលក់ភ្នំដែលជាទីកន្លែងសក្ការៈបូជា ជាទីកន្លែងដែលកាន់កាប់រួមរបស់ប្រជាពលរដ្ឋនៅក្នុងភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ក្នុងការលក់នេះមានមនុស្សមួយក្រុមដែលមានគ្នា៨ ទៅ៩នាក់ ដែលជាភាគីខាងដើមបណ្ដឹងក្នុងសំណុំរឿងនេះ ជាអ្នកលក់ឲ្យទៅអ្នកទិញ ហើយពេលបានលុយក៏យកមកចែកគ្នាអ្នកភូមិតាមខ្នងផ្ទះ។ តែពេលដែលអ្នកទិញចុះទៅធ្វើការឈូសឆាយកាប់រានលើដីនោះ បែរជាមានជនមួយក្រុមទៅធ្វើការតវ៉ាជំទាស់មិនឲ្យអ្នកទិញនោះធ្វើសកម្មភាពវិញ។

-នេះគឺជាវិវាទក្នុងការលក់ដីរួមរបស់សហកម្មសិទ្ធិ រវាងម្ចាស់កម្មសិទ្ធិទាំងអស់ក្នុងភូមិ (ដីមិនទាន់មានប័ណ្ណកម្មសិទ្ធិទេ) មិនមែនជាបទល្មើសញុះញង់ឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋដូចការចោទប្រកាន់នោះទេ។

-គប្បីឲ្យជនជាប់ចោទរួចផុតពីបទចោទ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្ដី

១.ឲ្យជនជាប់ចោទឈ្មោះ៖

ក.ឈ្មោះ [redacted] ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិពូង សញ្ជាតិខ្មែរ (ដែលមានសាវតារជាតិខាងលើ)

ខ.ឈ្មោះ [redacted] ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិពូង សញ្ជាតិខ្មែរ (ដែលមានសាវតារជាតិខាងលើ)

គ.ឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិពូង សញ្ជាតិខ្មែរ (ដែលមានសាវតារជាតិខាងលើ)

ឃ.ឈ្មោះ [redacted] ភេទស្រី អាយុ ៥៥ឆ្នាំ ជនជាតិពូង សញ្ជាតិខ្មែរ (ដែលមានសាវតារជាតិខាងលើ)

រួចផុតពីបទចោទ ក្នុងបទ៖ ញុះញង់ឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅភូមិពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០។

២.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី៕

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ធ្វើនៅមណ្ឌលគិរី,ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]